00154495

Declassified to Public
06 September 2012

**ជូនចំពោះលោកក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

យើងខ្ញុំ មេធាវី **ការ សាវុត្ថ** និងមេធាវី François Roux ការពារក្តីឲលោក **កាំង ហ្គេកអ៊ាវ** មានកិត្តិយសសូមស្នើសុំទៅលោកក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះមេត្តាប្រគល់អោយយើងខ្ញុំនូវឯកសារជាភាសាបារាំងអំពី "ចម្លើយតបរបស់សហព្រះរាជអាជ្ញា តបទៅបណ្តឹងឧទ្ធរណ៏របស់មេធាវីដែលប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតលើឈ្មោះកាំង ហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧" ដែលបានដាក់តម្កល់កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ នៅ ការិយាល័យក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ ជាភាសាខ្មែរ និងភាសាអង់គ្លេស និងបានប្រគល់មកឲ្យមេធាវីការពារក្តីកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧។

ដោយឡែក យើងខ្ញុំក៏សូមស្នើសុំទៅលោកក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ មេត្តាកត់សម្គាល់ថា យើងខ្ញុំសំណូមពរទទួលបាននូវឯកសារទាំងអស់ ដែលបានដាក់តម្កល់នៅអង្គបុរេជំនុំជម្រះ ជាភាសាខ្មែរ និងភាសាបារាំង ដោយអនុលោមតាមមាត្រា ២.២ នៃសេចក្តីណែនាំអនុវត្ត ០១/២០០៧ អំពីការដាក់ឯកសារ។

សូមលោកក្រឡាបញ្ជីមេត្តាទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ២០០៧

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
THE PRE - TRIAL CHAMBER OF THE ECCC
លេខ No.: 001
ថ្ងៃទី Date: 22-10-2007
ម៉ោងចូល Time: 9h25 AM

សម្រាប់សហមេធាវីទាំងពីរ
មេធាវីម្នាក់ក្នុងចំណោមសហមេធាវីទាំងពីរ
មេធាវី **ការ សាវុត្ថ**

<u>ចម្លងជូន៖</u>

លោក និងលោកស្រីចៅក្រមនៃអង្គបុរេជំនុំជម្រះទាំងអស់

ឯកឧត្តម ក្រាញ់ តូនី ប្រធានផ្នែកគ្រប់គ្រងតុលាការ